ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៤ ឆ្នាំ ២០០៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងតាមផែនការអន្តរក្រសួងមហាផ្ទៃ-ការពារជាតិ លេខ ០៣២ ជ.ក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៤
- យោងតាមការចាំបាច់

# ស ម្រេ ច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម | **ទៀ បាញ់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម | **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម | **ឯម សំអាន** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- ឯកឧត្តម | **ចាយ សាំងយុន** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៦- ឯកឧត្តម | **កែ គឹមយ៉ាន** | អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៧- ឯកឧត្តម | **ហុក ឡង់ឌី** | អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨- ឯកឧត្តម | **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៩- ឯកឧត្តម | ប្រធានគណៈបញ្ជាការឯកភាពគ្រប់ខេត្ត ក្រុង | | សមាជិក |

**ប្រការ២.-**

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ មានភារកិច្ចដូចតទៅ :

- សហការ និងសម្របសម្រួល ជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើការងារសន្តិសុខ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៤ ឆ្នាំ ២០០៨
- ចាត់តាំងកម្លាំងជំនាញ ពិសេសគណៈបញ្ជាការឯកភាពគ្រប់ខេត្ត-ក្រុង ដើម្បីសហការឱ្យបានជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាឱ្យការបោះឆ្នោតទាំងពីរ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ គ្មានការគំរាមកំហែង និងអំពើហិង្សា

- ផ្សព្វផ្សាយព័ត៌មាន គោលការណ៍ និងវិធានការផ្សេងៗ ស្តីពីការងារសន្តិសុខ ជូនគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ជ្រាប និងអនុវត្ត
- ប្រមូលផ្តុំព័ត៌មាន ពាក្យបណ្តឹងទាក់ទិននឹងសន្តិសុខ ពីគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់ ដើម្បីពិនិត្យ ដោះស្រាយ និងបញ្ជាណែនាំ
- ប្រមូលផ្តុំចាត់ចែងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ ដោយប្រើសម្ភារៈ ឧបករណ៍ និងមធ្យោបាយគ្រប់ប្រភេទរបស់អង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីរួមចំណែកអនុវត្តកិច្ចប្រតិបត្តិការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈឱ្យមានប្រសិទ្ធភាពខ្ពស់ ដល់ដំណើរការរៀបចំការបោះឆ្នោតទាំងពីរ ។

**ប្រការ៣ .-**

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការ និងមានសិទ្ធិប្រើប្រាស់ថវិកា និងត្រារបស់រាជរដ្ឋាភិបាល។

**ប្រការ៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ